# របាំក្ងោកប៉ៃលិន

នៅប្រទេសកម្ពុជា គេឃើញមានរបាំក្ងោកបីប្រភេទ គឺ៖ របាំក្ងោកពោធិសាត់ របាំក្ងោកភ្នំក្រវាញ និងរបាំក្ងោកប៉ៃលិន។

ខេត្តប៉ៃលិន ដែលមានព្រំប្រទល់ជាប់នឹងប្រទេសថៃឡង់ សម្បូណ៌ទៅដោយរ៉ែត្បូងដែលមានតម្លៃ។ ធនធាននេះត្រូវបានជនជាតិខ្មែរកូឡា ដែលមានដើមកំណើតជនជាតិភូមា និងបានមករស់នៅក្នុងតំបន់នេះជាច្រើនជំនាន់មកហើយនោះ ក៏បានទាញយកផលពីធនធានធម្មជាតិនេះ។ របរចិញ្ចឹមជីវិតសំខាន់ជាងគេរបស់ជនជាតិខ្មែរកូឡា គឺការជីកយករ៉ែត្បូងដ៏មានតម្លៃ។

មិនខុសគ្នានឹងខេត្តពោធិសាត់ ខេត្តប៉ៃលិនក៏មានរបាំក្ងោកដែលគេហៅថា «របាំក្ងោកប៉ៃលិន»។ សត្វក្ងោកជានិមិត្តរូបនៃសុភមង្គល។ ទោះបីជាប្រជាជនចូលចិត្តឬមិនចូលចិត្តធ្វើត្រាប់តាមសត្វក្ងោកក្ដី ក៏របាំនេះត្រូវបានគេបង្កើតឡើងនិងច្នៃប្រឌិតឱ្យមានលក្ខណៈរស់រវើកនិងទាក់ទាញ ដូចមាននៅលើពណ៌ដ៏ស្រស់ស្អាតនៃស្លាបក្ងោកជាដើម។ របាំក្ងោកប៉ៃលិន បង្ហាញពីការចែចង់រវាងសត្វក្ងោកឈ្មោលនិងក្ងោកញី។ របាំនេះត្រូវបានគេនិយាយថានាំមកនូវភាពសប្បាយរីករាយនិងភាពចម្រុងចម្រើនដល់អ្នកស្រុកអ្នកភូមិ។ ហេតុដូច្នេះហើយ បានជាយើងឃើញនៅក្នុងភូមិស្រុកនាខេត្តប៉ៃលិន របាំនេះត្រូវបានគេសម្ដែងក្នុងពិធីបុណ្យចូលឆ្នាំ និងឱកាសផ្សេងៗទៅតាមតម្រូវការ។

របាំក្ងោកប៉ៃលិន ត្រូវបានគេសម្រួលយកចេញពីរឿងនិទានដែលទាក់ទងនឹងសត្វក្ងោក និងព្រានព្រៃដូចតទៅ៖

មានព្រះនាងមួយអង្គបានផ្ទំយ៉ាងស្កប់ស្កល់និងសុបិន ឃើញសត្វក្ងោកដ៏សង្ហាមួយដែលចេះវេទមន្ត និងច្រៀងផង។ ក្នុងសុបិន ការច្រៀងរបស់សត្វក្ងោកនោះបានទាក់ទាញអារម្មណ៍ព្រះនាងយ៉ាងខ្លាំង។ ក្រោយពេលដែលព្រះនាងតើនឡើង ក៏គិតថាតើធ្វើយ៉ាងណាដើម្បីបានសត្វក្ងោកនោះមកច្រៀងឱ្យព្រះនាងស្ដាប់ម្ដងទៀត។ ព្រះនាងបានប្រែជាសោកសៅ មិនសោយក្រយា និងផ្ទំមិនលក់។ ដោយទតឃើញអាការៈមិនប្រក្រតីរបស់បុត្រី ព្រះរាជា ទ្រង់សួរទៅកាន់បុត្រី ហើយព្រះនាងក៏បានឆ្លើយទូលថ្វាយទៅព្រះវរបិតា

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

វិញ អំពីសុបិននិមិត្តរបស់ព្រះនាង និងសេចក្តីប្រាថ្នាចង់បានសត្វក្ងោកនោះមកចៀងថ្វាយព្រះនាង។

ព្រះរាជា ក៏បានត្រាស់បញ្ជាទៅព្រានព្រៃម្នាក់ដែលពូកែជាងគេនៅក្នុងព្រះរាជាណាចក្រឱ្យទៅស្វែងរកសត្វក្ងោកនោះ។ ក្រោយពីស្វែងរកសព្វទិសទីអស់ហើយ នាវេលាពេលព្រឹកមួយនោះ ព្រានព្រៃក៏បានឃើញសត្វក្ងោកមួយទំនៅលើមែកឈើ ហើយធ្វើសមាធិដោយបែរមុខទៅព្រះអាទិត្យ។ បន្ទាប់មក សត្វក្ងោកនោះក៏លោតចុះពីលើមែកឈើហើយរេរាំដោយក្តីរីករាយនិងសោមនស្ស។ ពេលនោះ ព្រានព្រៃក៏រៀបចំស្នានិងព្រួញប្រុងនឹងបាញ់ទៅលើសត្វក្ងោកកុំឱ្យវាហើរ ក្នុងគោលបំណងនឹងចាប់យកវាទៅថ្វាយព្រះរាជបុត្រីនៃព្រះរាជា។ ប៉ុន្តែ ព្រានព្រៃបាញ់មិនត្រូវសត្វក្ងោកនោះសោះ និងមានចម្ងល់យ៉ាងខ្លាំងថាហេតុអ្វី ឬក៏សត្វក្ងោកនោះមានសិល្ប៍វេទមន្តអាគមគាថាឬយ៉ាងណា?។

ពីរបីថ្ងៃបានកន្លងផុតទៅ ព្រានព្រៃបានតាមសង្កេតហើយដឹងថា សត្វក្ងោកនោះតែងតែងើបពីព្រលឹមនិងធ្វើសមាធិដោយដាក់ជើងទាំងពីររបៀបដូចជាសំពះ ទៅព្រះអាទិត្យនាទិសខាងកើត និងធ្វើដូចគ្នានៅពេលល្ងាចដោយដាក់ជើងសំពះទៅព្រះអាទិត្យនាទិសខាងលិច មុននឹងចូលដេក។ ព្រានព្រៃបានរកមធ្យោបាយបញ្ឈប់សត្វក្ងោកកុំឱ្យធ្វើសមាធិមួយថ្ងៃ ដើម្បីគេនឹងចាប់យកសត្វក្ងោកនោះឱ្យបាន។

នៅថ្ងៃបន្ទាប់ ព្រានព្រៃបានចាប់បានសត្វក្ងោកញីមួយយ៉ាងស្រស់ស្អាត ហើយក៏យកទៅលែងនៅក្នុងទីធ្លាខាងមុខកន្ទែងដែលសត្វក្ងោកឈ្មោលនោះរស់នៅ។ នាព្រឹកនោះ សត្វក្ងោកឈ្មោលងើបឡើង ទទះស្លាបប្រុងនឹងធ្វើសមាធិដូចធម្មតា ស្រាប់តែឃើញសម្រស់ដ៏ស្រស់ស្អាតរបស់ក្ងោកញីនៅនឹងភ្នែក។ សត្វក្ងោកឈ្មោលក៏ដើរឆ្ពោះទៅរកសត្វក្ងោកញី តែត្រូវព្រានព្រៃចាប់បាន។ សត្វក្ងោកឈ្មោល ក៏បានសួរទៅព្រានព្រៃថា «តើអ្នកចង់បានអ្វីពីខ្ញុំ? ខ្ញុំបានចាកចោលព្រៃព្រឹក្សា មកនៅក្នុងព្រៃដ៏ជ្រៅនេះ ដើម្បីឱ្យឆ្ងាយពីការបរបាញ់នៃព្រានព្រៃ។ ហេតុអ្វីក៏អ្នកចង់ធ្វើបាបខ្ញុំ?» បន្ទាប់ពីបានឮសត្វក្ងោកឈ្មោលរៀបរាប់ដូច្នោះហើយ ព្រានព្រៃក៏មានចិត្តអាណិតអាសូរដល់សត្វក្ងោក និងឆ្លើយតបទៅវិញដោយពាក្យផ្អែមល្ហែមថា៖ «នែម្នាលសត្វក្ងោក ខ្ញុំនឹងមិនសម្លាប់អ្នកឡើយ ដោយខ្ញុំបានឃើញថាអ្នកជាអ្នកកាន់សីល ធ្វើសមាធិជារៀងរាល់ព្រឹក។ ហេតុដូច្នេះហើយបានជា

*ខ្ញុំចាប់យកអ្នកទៅថ្វាយព្រះរាជបុត្រីនៃព្រះរាជា ព្រោះព្រះនាងបានសុបិននិមិត្តទៅឃើញសត្វក្ងោកមួយ ចេះច្រៀង ដែលព្រះនាងសព្វព្រះហឫទ័យចង់បានដើម្បីនឹងបានស្ដាប់វាច្រៀង»។ សត្វក្ងោកបានឮដូច្នោះ ក៏មានសេចក្ដីរីករាយសោមនស្សនិងឆ្លើយថា៖ «ដូច្នេះសូមព្រានកុំព្រួយ ខ្ញុំនឹងទៅច្រៀងថ្វាយព្រះនាងនៅរាល់ថ្ងៃសីលចាប់ពីថ្ងៃនេះតទៅ»។ ចាប់ពីពេលនោះមក សត្វក្ងោកក៏តែងតែទៅច្រៀងថ្វាយព្រះនាង។ ដោយជឿទៅលើជំនឿនេះ ខ្មែរកូឡានាខេត្តប៉ៃលិន និយមសម្ដែងរបាំក្ងោករបស់គេនៅរៀងរាល់ថ្ងៃសីល។*

*នៅពេលដែលសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈយករបាំនេះមកតម្លើង ធាតុដើមខ្លះនៃរបាំត្រូវបានគេដកចេញ ហើយធាតុថ្មីត្រូវបានគេបន្ថែម។ ប្រធានបទនិងខ្លឹមសាររបស់របាំ ត្រូវបានគេកែប្រែមកបង្ហាញពីការចែចង់រវាងក្ងោកញីនិងឈ្មោលវិញ។ វង់តន្ត្រីកំដររបាំក្ងោកប៉ៃលិន មាន៖ ស្គរដៃយ៉ាំ១ ស្គរក្ងោះ១គូ ស្រឡៃប៉ៃលិន១ ឆាប២គូ គងម៉ង់១ និងអ្នកច្រៀងម្នាក់ ដែលយើងឃើញមាននៅប្រើរហូតដល់សព្វថ្ងៃ។*

## ឯកសារពិគ្រោះ


Sam, Chan Moly, Nguon, Sam Ath, and Sam, Sam-Ang. (1989). *Khmer Folk Dance* (2nd ed.). Washington, DC: Cambodian Network Council.




*អត្ថបទដោយ៖ បណ្ឌិត សំ សំអាង*






អត្ថបទដោយ៖ បណ្ឌិត សំ សំអាង